**កំណត់សម្គាល់ការសិក្សា:** ម៉ូឌុលនេះត្រូវប្រើពេលប្រហែលប្រាំមួយម៉ោង ។ ប្រសិនបើអ្នកមានពេលតិចតួចអ្នកអាចផ្អាកការសិក្សាសិន ខណៈដែលម៉ូឌុលនេះសិក្សាបានប្រហែលពាក់កណ្ដាល មុននឹងសិក្សាបន្តទៅផ្នែកសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ។

# ម៉ូឌុល ៨: សន្ធិសញ្ញាស្ដីពីប្រព័ន្ធចុះបញ្ជីអន្តរជាតិ និងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មដែលគ្រប់គ្រងដោយដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោក

# ពាណិជ្ជសញ្ញា គំនូរឧស្សាហកម្ម និងប្រកាសនីយប័ត្រតក្កកម្ម

## គោលបំណង

បន្ទាប់ពីបានបញ្ចប់ការសិក្សានៃម៉ូឌុលនេះ អ្នកអាច ៖

១. ធ្វើជាតារាងស្ដីពីប្រព័ន្ធចុះបញ្ជីអន្តរជាតិ ដែលគ្រប់គ្រងដោយអង្គកម្មសិទ្ធិបញ្ញាពិភពលោក(WIPO) ។

២. គូរឌីយ៉ាក្រាម(diagram) ពន្យល់អំពីវិធីដំណើរការដែលអ្នកស្នើសុំអាចប្រើប្រព័ន្ធម៉ាឌ្រីដដើម្បីទទួលបានកិច្ចការពារពាណិជ្ជសញ្ញាក្នុងប្រទេសផ្សេងៗ ។

៣. ពិពណ៌នាអំពីតួនាទីរបស់ការិយាល័យអន្តរជាតិ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកក្នុងដំណើរការចុះបញ្ជី ។

៤. ពន្យល់ថាតើនឹងមានអ្វីកើតឡើង ប្រសិនបើពាណិជ្ជសញ្ញាត្រូវបានបដិសេធនៅក្នុងប្រទេសដើម ក្រោយពេលដែលចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិ ។

៥. បញ្ជាក់អំពីរយៈពេលដែលពាណិជ្ជសញ្ញាមួយអាចត្រូវបានការពារ ។

៦. ធ្វើជាតារាងស្ដីពីអត្ថប្រយោជន៍ នៃកិច្ចការពារគំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ ។

៧. ពន្យល់អំពីដំណើរការ នៃកិច្ចការពារអន្តរជាតិដែលផ្ដល់គំនូរឧស្សាហកម្មដោយកិច្ចព្រមព្រៀងទីក្រុងឡាអេ ។

៨. ពន្យល់អំពីគោលបំណងនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម(PCT) ឲ្យបាន១០០ ពាក្យ។

៩. ពិពណ៌នាអំពី អត្ថប្រយោជន៍សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មឲ្យបាន២០០ ពាក្យ។

១០. គូរឌីយ៉ាក្រាម ស្ដីអំពីដំណើរការដែលពាក់ព័ន្ធទៅនឹងការប្រើប្រាស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម។

©WIPO/OMPI

១១. ពន្យល់អំពី តួនាទីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកដែលមានចែងក្នុងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មឲ្យបាន ២០០ ពាក្យ ។

## សេចក្តីផ្តើម

តួនាទីភាគច្រើនដែលអង្គការកម្មសិទ្ធិបញ្ញាពិភពលោកជួយជម្រុញកម្មសិទ្ធិបញ្ញានោះគឺ តួនាទីគ្រប់គ្រងសន្ធិសញ្ញាជាក់លាក់ និងអនុសញ្ញាជាក់លាក់ ។ កិច្ចការពារពាណិជ្ជសញ្ញាអន្តរជាតិ គំនូរឧស្សាហកម្ម និងការហៅឈ្មោះតាមប្រភពដើមត្រូវអនុវត្តតាមរយៈប្រព័ន្ធចុះបញ្ជីបីយ៉ាង ៖ ប្រព័ន្ធពាណិជ្ជសញ្ញាទីក្រុងម៉ាឌ្រីដ ប្រព័ន្ធគំនូរឧស្សាហកម្មទីក្រុងឡាអេ និងកិច្ចព្រមព្រៀងសម្រាប់កិច្ចការពារការហៅឈ្មោះតាមប្រភពដើម ។ ផ្នែកដំបូងនៃម៉ូឌុលនេះនឹងផ្តោតលើតួនាទីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកលើការគ្រប់គ្រងប្រព័ន្ធការពារពាណិជ្ជសញ្ញា និងគំនូរឧស្សាហកម្ម ។

ផ្នែកទីពីរនៃម៉ូឌុលនេះពាក់ព័ន្ធទៅនឹងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ។ នេះគឺ ជាសន្ធិសញ្ញាដែលគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោកចំពោះប្រាក់ចំណូលដែលទទួលបានដើម្បីជួយសម្រួលដល់ការដាក់ពាក្យស្នើសុំក្នុងប្រទេសផ្សេងៗ ។

ម៉ូឌុលនេះចាប់ផ្តើមពិពណ៌នាអំពីប្រព័ន្ធចុះបញ្ជីអន្តរជាតិ ។

## ប្រព័ន្ធចុះបញ្ជី

ជាបឋម ចូរអ្នកស្តាប់ភាគនៃសម្លេងដូចតទៅនេះ ។

***ភាគនៃសម្លេង ១ ៖*** តើប្រព័ន្ធចុះបញ្ជីអន្តរជាតិនៅក្រៅប្រទេសដែលធ្វើឡើងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោកមានលក្ខណៈខុសគ្នាប៉ុន្មានយ៉ាង?

បច្ចុប្បន្នមានប្រព័ន្ធបីយ៉ាង ។ តើអ្វីទៅដែលត្រូវបានគេស្គាល់ថាជាប្រព័ន្ធម៉ាឌ្រីដសម្រាប់ការចុះបញ្ជីពាណិជ្ជសញ្ញាអន្តរជាតិ និងត្រូវបានគ្រប់គ្រងដោយសន្ធិសញ្ញាចំនួនពីរសម្រាប់បំពេញបន្ថែមគ្នាទៅវិញទៅមក ។ សន្ធិសញ្ញាទាំងពីរនោះគឺកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ និងពិធីសារម៉ាឌ្រីដ ។ ដូច្នេះមានប្រព័ន្ធចុះបញ្ជីអន្តរជាតិ ឬការដាក់តម្កល់គំនូរឧស្សាហកម្មឲ្យកាន់តែមានភាពត្រឹមត្រូវដែលត្រូវបានគ្រប់គ្រងដោយកិច្ចព្រមព្រៀងទីក្រុងឡាអេ ។ ទីបីគឺប្រព័ន្ធចុះបញ្ជីការហៅឈ្មោះតាមប្រភពដើមជាលក្ខណៈអន្តរជាតិក្រោមកិច្ចព្រមព្រៀងទីក្រុងលីស្បោន ។ ប៉ុន្តែប្រព័ន្ធដែលបានលើកឡើងចុងក្រោយនេះមិនប្រាកដថាធ្វើឲ្យប៉ះពាល់ដល់អ្នកកាន់កាប់សិទ្ធិគំនូរឧស្សាហកម្មឯកជន ថាជាការហៅឈ្មោះដែលត្រូវបានចុះបញ្ជីតាមសំណើររបស់រដ្ឋាភិបាលនានា ( ម៉ូឌុលនេះមិនគ្របដណ្តប់កិច្ចព្រមព្រៀងនេះឡើយ ) ។ ជាលទ្ធផល សកម្មភាពរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកភាគច្រើនត្រូវតែការពារពាណិជ្ជសញ្ញា និងគំនូរឧស្សាហកម្មនិងប្រកាសនីយប័ត្រតក្កកម្មតាមរយៈការចុះបញ្ជីអន្តរជាតិ ។

©WIPO/OMPI

**សំណួរវាយតម្លៃខ្លួនឯង(SAQ)**

**សំណួរវាយតម្លៃខ្លួនឯង១ (SAQ 1) ៖ ក)- តើប្រព័ន្ធកម្មសិទ្ធិបញ្ញាខាងក្រោមពាក់ព័ន្ធនឹង៖ ប្រព័ន្ធទីក្រុងឡាអេ ប្រព័ន្ធទីក្រុងម៉ាឌ្រីត និងប្រព័ន្ធទីក្រុងលីស្បោន ដូចម្តេចខ្លះ ?**

**ខ)- តើប្រព័ន្ធទាំងពីរបង្កើតជាប្រព័ន្ធទីក្រុងម៉ាឌ្រីត បានយ៉ាងដូចម្តេច?**

ចូរអ្នកសរសេរចម្លើយរបស់អ្នកនៅត្រង់នេះ

| |
|---|
| |

ចូរអ្នកចុចត្រង់នេះដើម្បីមើលម្លើយ

**សំណួរវាយតម្លៃខ្លួនឯង១ (SAQ 1) ចម្លើយ ៖**

**ក)**-ប្រព័ន្ធទីក្រុងឡាអេគ្របដណ្តប់ការដាក់តម្កល់គំនូរឧស្សាហកម្ម ប្រព័ន្ធចុះបញ្ជីពាណិជ្ជសញ្ញាទីក្រុងម៉ាឌ្រីដ និងកិច្ចព្រមព្រៀងទីក្រុងលីស្បោនពាក់ព័ន្ធនឹងការចុះបញ្ជីការហៅឈ្មោះតាមប្រភពដើម ។

**ខ)**-សន្ធិសញ្ញាទាំងពីរក្នុងប្រព័ន្ធទីក្រុងម៉ាឌ្រីតគឺ ជាកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដស្តីអំពីការចុះបញ្ជីម៉ាកអន្តរជាតិ(១៨៩១) និងពិធីសារទីក្រុងម៉ាឌ្រីដពាក់ព័ន្ធទៅនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ(១៩៨៩) ។

## ប្រព័ន្ធទីក្រុងម៉ាឌ្រីដ ៖
## ការចុះបញ្ជីពាណិជ្ជសញ្ញាជាលក្ខណៈអន្តរជាតិ

ឥឡូវនេះ ចូរអ្នកស្តាប់ភាគនៃសម្លេងបន្ទាប់ដើម្បីស្វែងយល់អំពីវិធីដែលប្រព័ន្ធទីក្រុងម៉ាឌ្រីតជួយដល់កិច្ចការពារពាណិជ្ជសញ្ញាអន្តរជាតិ។

**ភាគនៃសម្លេង ២ ៖** តើអ្នកស្នើសុំអាចទទួលបានពាណិជ្ជសញ្ញាអន្តរជាតិពី ប្រព័ន្ធទីក្រុងម៉ាឌ្រីដដូចម្តេចខ្លះ ?

ជាបឋម ដើម្បីឆ្លើយសំណួរហ្នឹង ខ្ញុំត្រូវពន្យល់អំពីវិធីដែលប្រព័ន្ធចុះបញ្ជីជាលក្ខណៈអន្តរជាតិអាចដំណើរការទៅបាន ។ គេដាក់ពាក្យស្នើសុំជាលក្ខណៈអន្តរជាតិនៅការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកនៅទីក្រុងហ្សឺណែវ ហើយនៅការិយាល័យនោះពួកគេបាន

©WIPO/OMPI

កំណត់អំពី ប្រទេសដែលជាភាគីនៃសន្ធិសញ្ញាដែលពួកគេចង់បានម៉ាកមួយត្រូវបានការពារ ។ យើងខ្ញុំចុះបញ្ជីម៉ាក និងបញ្ជូនវាទៅឲ្យប្រទេសដែលបានកំណត់នោះវិញទើបមានលទ្ធភាពធ្វើការបដិសេធកិច្ចការពារនោះ ។ ជាទូទៅ ពួកគេធ្វើការត្រួតពិនិត្យម៉ាកទោះបីជាម៉ាកនោះត្រូវបានដាក់ដោយផ្ទាល់ក៏ដោយនិងអនុវត្តលក្ខណៈវិនិច្ឆ័យនៅថ្នាក់ជាតិរបស់ខ្លួនជាធម្មតា ។ ប្រសិនបើពួកគេធ្វើការបដិសេធម៉ាក ការបដិសេធនោះត្រូវជូនដំណឹងមកយើងខ្ញុំវិញ និងត្រូវចុះក្នុងបញ្ជីអន្តរជាតិប្រឆាំងនឹងម៉ាករបស់ប្រទេសនោះ ។ ប៉ុន្តែ ម្យ៉ាងទៀត បុគ្គលម្នាក់អាចធានាការចុះបញ្ជីជាលក្ខណៈអន្តរជាតិ ថាតើម៉ាកនោះត្រូវបានការពារនៅក្នុងប្រទេសជាក់លាក់មួយដែលត្រូវបានកំណត់ដោយប្រទេសនោះ ដែរ ឬអត់។

រូបលេខ ១ ពិពណ៌នាអំពីដំណើរការចុះបញ្ជីពាណិជ្ជសញ្ញាជាលក្ខណៈអន្តរជាតិ




©WIPO/OMPI

ចូរអ្នកស្ដាប់ភាគនៃសម្លេងបន្ទាប់ ដើម្បីស្វែងយល់អំពីតួនាទីរបស់ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកឲ្យកាន់តែប្រសើរឡើង ។ <u>សូមចុចត្រង់នេះដើម្បីមើលបញ្ជីឈ្មោះប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀង និងពិធីសារទីក្រុងម៉ាឌ្រីដ</u> ។

***ភាគនៃសម្លេង ៣ ៖*** ដូច្នេះការិយាល័យអន្តរជាតិមានតួនាទីទទួលពាក្យស្នើសុំ និងបន្ទាប់មកបញ្ជូនវាទៅឲ្យប្រទេសដែលបានកំណត់រួចនោះវិញ ។ តើបច្ចុប្បន្នការិយាល័យអន្តរជាតិត្រួតពិនិត្យពាណិជ្ជសញ្ញា ដែរឬទេ ?

ការិយាល័យអន្តរជាតិពុំបានត្រួតពិនិត្យខ្លឹមសារទេ ។ ជាគោលការណ៍ មានបញ្ហាជាក់លាក់ពីរដែលត្រូវបានស៊ើបអង្កេតដោយការិយាល័យថ្នាក់ជាតិ ។ បញ្ហាទី១ថាតើម៉ាកអាចមានតួនាទីជាពាណិជ្ជសញ្ញាដែរឬទេ ម្យ៉ាងទៀត ថាតើវាអាចបង្ហាញពីភាពខុសគ្នានៃទំនិញ និងសេវាដែរ ឬទេ និង បញ្ហាផ្សេងទៀតថាតើវាធ្វើឲ្យប៉ះពាល់ដល់ឈ្មោះម៉ាករបស់អ្នកដ៏ទៃ ដែលបានការពាររួចហើយនោះដែរឬទេ ។ បច្ចុប្បន្នប្រទេសទាំងនោះមានគំនិតខ្វែងគ្នាខ្លាំងក្នុងតំណោះស្រាយចំពោះការត្រួតពិនិត្យនេះ ។ អ្នកខ្លះត្រួតពិនិត្យបានពេញលេញ និងអ្នកខ្លះទៀតមិនបានពេញលេញទេ ។ ការិយាល័យអន្តរជាតិមិនបានធ្វើការត្រួតពិនិត្យណាមួយចំពោះទិដ្ឋភាពជាក់ស្ដែងឡើយ ផ្ទុយទៅវិញច្រើនតែទុកវាទៅឲ្យច្បាប់នៃប្រទេសពាក់ព័ន្ធទាំងស្រុង ។ ទោះយ៉ាងដូច្នេះក្ដី ជាបឋម ការិយាល័យអន្តរជាតិធ្វើការត្រួតពិនិត្យពាក្យស្នើសុំដែលអនុលោមតាមលក្ខខណ្ឌ ផ្លូវការដូចមានចែងក្នុងសន្ធិសញ្ញា និងបទប្បញ្ញត្តិ ដើម្បីធ្វើឲ្យប្រាកដថាពាក្យស្នើសុំពាណជ្ជសញ្ញាពិតជាមានសមាសធាតុចាំបាច់ ។ ការិយាល័យអន្តរជាតិធ្វើការត្រួតពិនិត្យផងដែរអំពីបញ្ជីឈ្មោះទំនិញ និងសេវាដែលត្រូវបានការពារ និងត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំពាណិជ្ជសញ្ញាទំនិញនិងសេវាទាំងនោះត្រូវបានចាត់ជាចំណាត់ថ្នាក់តាមចំណាត់ថ្នាក់អន្តរជាតិ ត្រូវបានគេស្គាល់ថាជាចំណាត់ថ្នាក់នីស ហើយការិយាល័យអន្តរជាតិទទួលខុសត្រូវរួមចំពោះពាក្យស្នើសុំដែលអនុលោមទៅតាមចំណាត់ថ្នាក់។ដូច្នេះ ការិយាល័យអន្តរជាតិមិនបានធ្វើការត្រួតពិនិត្យបែបបទ និងចំណាត់ថ្នាក់នៃទំនិញ និងសេវាទេ មានន័យថាកិច្ចការទាំងនោះមិនត្រូវបានអនុវត្តដោយការិយាល័យទទួលពាក្យស្នើសុំឡើយពីព្រោះពួកគេទទួលស្គាល់ថា ពួកគេទទួលពាក្យស្នើសុំដែលបានដាក់ និងពាក្យស្នើសុំចំណាត់ថ្នាក់នោះបានត្រឹមត្រូវហើយ ។

ដូច្នេះ តួនាទីរបស់ការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោកគឺទទួលពាក្យស្នើសុំកិច្ចការពារពាណិជ្ជសញ្ញាក្នុងប្រទេសមួយចំនួនដែលបានកំណត់ ។ អង្គការកម្មសិទ្ធិបញ្ញាពិភពលោកត្រួតពិនិត្យមើលក្នុងករណីដែលពាក្យស្នើសុំត្រូវបានធ្វើតាមបែបបទត្រឹមត្រូវ និងចុះបញ្ជីម៉ាកក្នុងករណីត្រឹមត្រូវ និងបញ្ជូនម៉ាកនោះទៅឲ្យប្រទេសដែលបានកំណត់រួច ។ ការត្រួតពិនិត្យលើខ្លឹមសារអាចត្រូវបានធ្វើក្នុងប្រទេសដែលបានកំណត់ប្រសិនបើច្បាប់របស់ប្រទេសពួកគេដាក់បញ្ញត្តិតឹងតែង ។

©WIPO/OMPI

ឥឡូវនេះ ចូរអ្នកស្តាប់ភាគនៃសម្លេងបន្ទាប់ដើម្បីស្វែងយល់ពីសារៈសំខាន់ក្នុងទទួលបានកិច្ចការពារនៅក្នុង "ប្រទេសដើម" របស់អ្នកស្នើសុំ ។

**ភាគនៃសម្លេង៤៖** តើវាចាំបាច់ដែរ ឬទេ សម្រាប់បុគ្គលម្នាក់ដែលតម្រូវឲ្យចុះបញ្ជីពាណិជ្ជសញ្ញារបស់ខ្លួននៅក្នុងប្រទេសដើមខ្លួនសិន មុននឹងគាត់អាចដាក់ពាក្យស្នើសុំជាលក្ខណៈអន្តរជាតិក្រោមប្រព័ន្ធទីក្រុងម៉ាឌ្រីដបាន ។

បាទ/ចាស នេះជាលក្ខខណ្ឌគ្រឹះនៃប្រព័ន្ធចុះបញ្ជីជាលក្ខណៈអន្តរជាតិ ។ ជាង១០០ឆ្នាំមកហើយនៅពេលដែលប្រព័ន្ធនេះបានចាប់ផ្តើមគឺពិតជាមានបំណងចង់បានមធ្យោបាយមួយដើម្បីពង្រីកកិច្ចការពារដែលផ្តល់ តាមរយៈការចុះបញ្ជីនៅក្នុងស្រុកចំពោះប្រទេសផ្សេងៗនៃសហភាពទីក្រុងម៉ាឌ្រីដ ។ ប្រព័ន្ធនេះមានភាពជឿនលឿនច្រើន និងមានភាពស្មុកស្មាញច្រើនតាំងពីពេលនោះមក ប៉ុន្តែគោលការណ៍គ្រឹះនៅតែបន្តដែលជំណាក់ការដំបូងអ្នកត្រូវតែចុះបញ្ជីនៅប្រទេសដើមរបស់អ្នក ឬយ៉ាងហោចណាស់អ្នកត្រូវដាក់ពាក្យស្នើសុំចុះបញ្ជីនៅប្រទេសរបស់អ្នក ក្នុងករណីដែលពាក្យស្នើសុំជាលក្ខណៈអន្តរជាតិត្រូវបានទទួលសិទ្ធិផ្តាច់មុខក្រោមពិធីសារ ។

**ភាគនៃសម្លេង៥៖** អ្នកប្រើប្រាស់ប្រព័ន្ធអន្តរជាតិ តាមរយៈការដាក់ពាក្យស្នើសុំចុះបញ្ជីទីក្រុងម៉ាឌ្រីដប៉ុន្តែបន្ទាប់ពីអ្នកបានដាក់ពាក្យស្នើសុំជាលក្ខណៈអន្តរជាតិ ពាក្យស្នើសុំថ្នាក់ជាតិត្រូវបានបដិសេធ។ តើមានអ្វីកើតឡើងនៅក្នុងហេតុការណ៍នោះ?

ក្នុងករណីដែលពាក្យស្នើសុំត្រូវបានបដិសេធ ពិតជាមានលទ្ធផលស៊ីគ្នាសង្វាក់គ្នាចំពោះការចុះបញ្ជីជាលក្ខណៈអន្តរជាតិ ។ មានចំណងទាក់ទងឯករាជ្យមួយរវាងកិច្ចការពារថ្នាក់ជាតិ និងកិច្ចការពារជាលក្ខណៈអន្តរជាតិសម្រាប់រយៈពេល ៥ (ប្រាំ) ឆ្នាំ ។ ប៉ុន្តែក្នុងករណីដែលអ្នកបានលើកឡើងនេះ ក្នុងកំឡុងពេល ៥ (ប្រាំ) ឆ្នាំ ប្រហែលជាឆាប់ៗខាងមុខនេះ ក្រោយពីពេលចុះបញ្ជីជាលក្ខណៈអន្តរជាតិដែលត្រូវបានអនុវត្តនឹងបណ្តាលឲ្យការចុះបញ្ជីជាលក្ខណៈអន្តរជាតិនោះត្រូវបានបដិសេធ ។ ក្នុងករណីដែលការបដិសេធនៅកំរិតថ្នាក់ជាតិមានភាពលំអៀងការបដិសេធនោះក៏មានភាពលំអៀងដូចគ្នា។

©WIPO/OMPI

## សំណួរវាយតម្លៃខ្លួនឯង(SAQ

**សំណួរវាយតម្លៃខ្លួនឯង២ (SAQ 2) ៖** ចូរអ្នកស្រមៃស្រម័យថាអ្នកបានចុះបញ្ជីពាណិជ្ជសញ្ញាមួយនៅក្នុងប្រទេសដើមរបស់អ្នក និងបន្ទាប់មក អ្នកទទួលបានការចុះបញ្ជីជាលក្ខណៈអន្តរជាតិ ដែលត្រូវបានចូលជាធរមានតាមលំដាប់ប្រទេសផ្សេងៗដែលរួមមានប្រទេសKenyaជាដើម។ បន្ទាប់ពីពេលដែលអ្នកបានដាក់ពាក្យស្នើសុំជាលក្ខណៈអន្តរជាតិបានមួយឆ្នាំទើបអ្នកដឹងថាប្រទេសដើមរបស់អ្នកបានលុបចោលការចុះបញ្ជីពាណិជ្ជសញ្ញារបស់អ្នក។ តើអ្នកនៅតែទទួលបានកិច្ចការពារនៅប្រទេសKenyaតាមប្រព័ន្ធទីក្រុងម៉ាឌ្រីដដែរឬទេ?

ចូរអ្នកសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ

| |
|---|
| |

ចូរអ្នកចុចត្រង់នេះដើម្បីមើលម្លើយ

**សំណួរវាយតម្លៃខ្លួនឯង២(SAQ 2) ចម្លើយ ៖**

ចម្លើយគឺទេ ក្នុងករណីដែលការចុះបញ្ជីគោលលែងមានហេតុផលណាមួយ ( ការលុបចោលតាមតំណែង ឬតាមសំណូមពររបស់ភាគីទីបី ឬការដែលមិនបានចុះបញ្ជីសាជាថ្មី ) ក្នុងកំឡុងពេល ៥ (ប្រាំ) ឆ្នាំដំបូង នៃអាយុកាល នៃការចុះបញ្ជីជាលក្ខណៈអន្តរជាតិ អានុភាពនេះនាំដល់ការចុះបញ្ជីអន្តរជាតិ ។ នេះគឺជាករណីដែលការចុះបញ្ជីជាលក្ខណៈអន្តរជាតិដែលត្រូវបានផ្អែកលើពាក្យស្នើសុំក្នុងប្រទេសដើមផងដែរហើយ ពាក្យស្នើសុំនោះត្រូវបានបដិសេធក្នុងកំឡុងពេលនោះ ។ យ៉ាងណាមិញ បន្ទាប់ពីពេលផុតកំណត់នៃរយៈពេល ៥ (ប្រាំ) ឆ្នាំនេះ ការចុះបញ្ជីជាលក្ខណៈអន្តរជាតិបានក្លាយជាឯករាជ្យចំពោះពាណិជ្ជសញ្ញានៅក្នុងប្រទេសដើមនឹងបន្តមានប្រសិទ្ធិភាព ទោះបីជាការចុះបញ្ជីនៅប្រទេសដើមនោះត្រូវបានបដិសេធក៏ដោយ ។

ដើម្បីរកឲ្យឃើញនូវរយៈពេល ចំពោះពាណិជ្ជសញ្ញាមួយ ដែលអាចត្រូវបានការពារជាលក្ខណៈអន្តរជាតិនោះ ចូរអ្នកស្តាប់ភាគនៃសម្លេង ។

©WIPO/OMPI

**ភាគនៃសម្លេង៦៖** តើអ្នកអាចការពារពាណិជ្ជសញ្ញាមួយ បានយូរប៉ុណ្ណា ?

ជាការពិត អ្នកអាចការពារពាណិជ្ជសញ្ញាមួយដោយគ្មានកំណត់ពេលវេលា ប៉ុន្តែក្នុងប្រព័ន្ធជាលក្ខណៈអន្តរជាតិ និងក្នុងប្រព័ន្ធថ្នាក់ជាតិផងដែរ យូរៗម្តងអ្នកត្រូវតែចុះបញ្ជីម៉ាកនោះសាជាថ្មី ។ ការចុះបញ្ជីជាលក្ខណៈអន្តរជាតិត្រូវបានចុះបញ្ជីសាជាថ្មីតាមរយៈការបង់កម្រៃសេវាម្តងទៀតជារៀងរាល់ ១០ (ដប់) ឆ្នាំម្តង ហើយខ្ញុំគិតថារយៈពេល១០ (ដប់) ឆ្នាំនេះគឺជាពាក្យបទដ្ឋានមួយនៅកំរិតថ្នាក់ជាតិ ប៉ុន្តែ ដូចខ្ញុំបាននិយាយរួចហើយ ពុំមានការកំណត់ពេលវេលាទេចំពោះម៉ាកដែលអាចត្រូវបានចុះបញ្ជីសាជាថ្មីនោះ។

ដូច្នេះ ប្រព័ន្ធទីក្រុងម៉ាឌ្រីដជាវិធីមួយដ៏មានសារៈសំខាន់ដែលអ្នកប្រើប្រាស់ពាណិជ្ជសញ្ញាអាចអនុវត្តកិច្ចការពារក្នុងប្រទេសមួយចំនួនក្នុងពេលតែមួយ ។ យ៉ាងណាមិញ ការសម្រេចថាតើត្រូវបដិសេធកិច្ចការពារចំពោះពាណិជ្ជសញ្ញាពិសេសមួយនៅក្នុងប្រទេសជាក់លាក់មួយ ដោយផ្អែកលើប្រព័ន្ធថ្នាក់ជាតិពាក់ព័ន្ធ ដែរ ឬអត់ ។ ក្នុងករណីដែលកិច្ចការពារមិនត្រូវបានបដិសេធម៉ាកនោះត្រូវបានពន្យារពេលដោយគ្មានកំណត់ ។

ប្រព័ន្ធចុះបញ្ជីម៉ាកជាលក្ខណៈអន្តរជាតិផ្តល់អត្ថប្រយោជន៍ជាច្រើនចំពោះម្ចាស់ពាណិជ្ជសញ្ញា ។ បន្ទាប់ពីការចុះបញ្ជីម៉ាក ឬការដាក់ពាក្យស្នើសុំចុះបញ្ជីនៅការិយាល័យប្រភពដើមរួចមកម្ចាស់ពាណិជ្ជសញ្ញាត្រូវតែដាក់ពាក្យស្នើសុំតែមួយលើកប៉ុណ្ណោះ ជាភាសាតែមួយ ទៅការិយាល័យតែមួយ និងត្រូវបង់កម្រៃសេវាទៅឲ្យការិយាល័យតែមួយ ។ រឿងនេះត្រូវបានធ្វើឡើងជំនួសការដាក់ពាក្យស្នើសុំដាច់ដោយឡែកនៅការិយាល័យពាណិជ្ជសញ្ញាក្នុងប្រទេសផ្សេងៗ ជាភាសាខុសៗគ្នា និងជំនួសនូវការបង់កម្រៃសេវាដាច់ដោយឡែកៗនៅការិយាល័យនីមួយៗ ។ អត្ថប្រយោជន៍ប្រហាក់ប្រហែលអាចកើតឡើងបានគឺនៅពេលដែលការចុះបញ្ជីនោះត្រូវបានចុះបញ្ជីសាជាថ្មី ឬកែប្រែ ។

## ប្រព័ន្ធទីក្រុងឡាអេ ៖
## កិច្ចការពារគំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ

ដូចបានលើកឡើងនៅក្នុងសេចក្តីផ្តើមនៃម៉ូឌុលនេះ ប្រព័ន្ធនៃកិច្ចការពារទីក្រុងឡាអេពាក់ព័ន្ធនឹងកិច្ចការពារគំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ ។

តើអ្នកអាចទទួលបានកិច្ចការពារគំនូរឧស្សាហកម្មនៅទូទាំងពិភពលោក ដែរ ឬទេ ?

©WIPO/OMPI

ជាទូទៅ កិច្ចការពារគំនូរឧស្សាហកម្មត្រូវបានកំណត់ចំពោះប្រទេសដែលកិច្ចការពារនោះត្រូវបានស្នើសុំ និងត្រូវបានផ្តល់ឲ្យ ។ ក្នុងករណីដែលកិច្ចការពារត្រូវបានប្រទេសជាច្រើនប្រាថ្នាចង់បាននោះ ពាក្យស្នើសុំថ្នាក់ជាតិដាច់ដោយឡែក ( ឬការដាក់តម្កល់ ) និងនីតិវិធីនានាដែលត្រូវបានធ្វើឡើងជាទូទៅមានលក្ខណៈខុសៗគ្នាតាមប្រទេសនីមួយៗ ។ យ៉ាងណាមិញ កិច្ចព្រមព្រៀងទីក្រុងឡាអេស្តីពីការដាក់តម្កល់គំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិបានជួយសម្រួលដល់ដំណើរការនេះ ។

តើការដាក់តម្កល់គំនូរឧស្សាហកម្មជាលក្ខណៈអន្តរជាតិ មានគោលបំណងដូចម្តេច ?

គោលបំណងសំខាន់របស់ប្រព័ន្ធទីក្រុងឡាអេគឺ ដើម្បីមានលទ្ធភាពការពារនូវការទទួលបានគំនូរឧស្សាហកម្មមួយ ឬច្រើនចំពោះប្រទេសមួយចំនួនតាមរយៈការដាក់ពាក្យស្នើសុំដាក់តម្កល់តែមួយលើកនៅការិយាល័យអន្តរជាតិ នៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។ម្យ៉ាងទៀត កិច្ចព្រមព្រៀងទីក្រុងឡាអេដែលត្រូវបានគ្រប់គ្រងដោយអង្គការកម្មសិទ្ធិបញ្ញាពិភពលោកបានអនុញ្ញាតឲ្យពលរដ្ឋ និងអ្នកស្រុក ឬក្រុមហ៊ុនចូលរួមជាភាគីរដ្ឋមួយ នៃកិច្ចព្រមព្រៀងដើម្បីទទួលបានកិច្ចការពារគំនូរឧស្សាហកម្មពីប្រទេសមួយចំនួនដែលជាភាគីនៃកិច្ចព្រមព្រៀងនេះផងដែរតាមរយៈនីតិវិធីដ៏សាមញ្ញមួយ ។ ការដាក់តម្កល់ជាលក្ខណៈអន្តរជាតិតែមួយលើក ជាភាសាតែមួយ ( អង់គ្លេស ឬបារាំង ) ដែលពាក់ព័ន្ធនឹងការចំណាយតែមួយលើក និងការដាក់ពាក្យស្នើសុំនៅការិយាល័យតែមួយគឺគ្រប់គ្រាន់តាមតម្រូវការ ។

ការិយាល័យនោះអាចជាការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ឬប្រហែលជាការិយាល័យថ្នាក់ជាតិ នៃរដ្ឋដែលជាភាគីហត្ថលេខីក្នុងករណីដែលរដ្ឋនេះអនុញ្ញាតឲ្យទាំងស្រុង ។ ការដាក់តម្កល់ជាលក្ខណៈអន្តរជាតិមិនបានទាមទារឲ្យមានការដាក់តម្កល់ណាមួយឡើយ។ នៅពេលដែលគំនូរឧស្សាហកម្មជាកម្មវត្ថុ នៃការដាក់តម្កល់ជាលក្ខណៈអន្តរជាតិបែបនេះ វាអាចទទួលនូវកិច្ចការពារដែលនឹងត្រូវបានទទួលនៅក្នុងប្រទេសនីមួយៗដែលបានចុះឈ្មោះរួចហើយទោះបីជាអ្នកស្នើសុំនោះបានអនុវត្តដោយផ្ទាល់ចំពោះប្រទេសនោះក៏ដោយ ឲ្យតែប្រទេសពិសេសនោះមិនបានបដិសេធកិច្ចការពារពិតប្រាកដ ។

កម្មសិទ្ធិបញ្ញាទាំងអស់សុទ្ធតែមានសារៈសំខាន់ក្នុងធានាឲ្យបាននូវកិច្ចការពាររបស់ខ្លួន ហើយភាគនៃសម្លេងបន្ទាប់នឹងផ្តល់អត្ថប្រយោជន៍ខ្លះៗ ស្តីពី កិច្ចការពារគំនូរឧស្សាហកម្មនេះ ។

តើអត្ថប្រយោជន៍នៃប្រព័ន្ធទីក្រុងឡាអេ មានអ្វីខ្លះ ?

ប្រព័ន្ធនេះផ្តល់លទ្ធភាពដល់ម្ចាស់គំនូរឧស្សាហកម្ម ក្នុងការទទួលបាននូវគំនូរដែលត្រូវបានការពារនៅក្នុងប្រទេសជាច្រើនតាមរយៈការដាក់ពាក្យស្នើសុំដ៏សាមញ្ញមួយនៅការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ជាភាសាតែមួយ ចំនួនមួយឈុត នៃកម្រៃសេវាជារូបិយវត្ថុមួយ ( ហ្វ្រង់

©WIPO/OMPI

ស្វ៊ីស ) ។ ប្រព័ន្ធទីក្រុងឡាអេបានជួយសម្រួលដ៏ទូលំទូលាយផងដែរលើការគ្រប់គ្រងគំនូរឧស្សាហកម្ម ជាបន្តបន្ទាប់តាំងពីពេលដែលវាមានលទ្ធភាពកត់ត្រានូវការផ្លាស់ប្តូរជាបន្តបន្ទាប់ ឬចុះបញ្ជីការដាក់តម្កល់សាជាថ្មីតាមរយៈជំហាន នៃនីតិវិធីតែមួយយ៉ាងសាមញ្ញនៅការិយាល័យអន្តរជាតិនៃអង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

**ភាគនៃសម្លេង៧៖** អ្នកអាចសង្ខេបបានឬទេ តើមានអត្ថប្រយោជន៍អ្វីខ្លះក្នុងការទទួលបានពីកិច្ចការពារគំនូរឧស្សាហកម្ម ?

យល់ព្រម អ្នកទទួលបានសិទ្ធិផ្តាច់មុខលើការប្រើប្រាស់គំនូរចំពោះសិទ្ធិនៃកម្មសិទ្ធិឧស្សាហកម្មទាំងអស់ ។ ម្យ៉ាងទៀត អ្នកគួរប្រដាប់សម្រាប់ខ្ទង់ដកយកផ្នែកដ៏ទំនើបដែលខ្ញុំទើបបានពិពណ៌នាឬអ្នកធ្វើសង្ហារឹមបែបម៉ូតថ្មី ឬក្រណាត់សំពត់បែបម៉ូតថ្មី ឬសំលៀកបំពាក់ដែលផលិតក្រៅអំពីសាច់ក្រណាត់ទាំងនោះទទួលបាននូវសិទ្ធិផ្តាច់មុខក្នុងការផលិត និងលក់ចេញតាមវិធីតែមួយដូចគ្នាទៅនឹងបុគ្គលដែលមានប្រកាសនីយបត្រតក្កកម្មគឺ មានសិទ្ធិផ្តាច់មុខនៅក្នុងកិច្ចដំណើរការប្រកាសនីយបត្រតក្កកម្មនោះ។

ប្រកាសនីយបត្រតក្កកម្មមួយប្រើប្រាស់មានរយៈពេលកំណត់ ។ តើវាមានលក្ខណៈដូចគ្នាទៅនឹងការចុះបញ្ជីគំនូរឧស្សាហកម្មដែរឬទេ?

បាទ/ចាស ប្រកាសនីយបត្រតក្កកម្មប្រើប្រាស់សម្រាប់រយៈពេលមួយមានកំណត់ប៉ុន្តែពុំដូចគ្នាទាំងអស់ទេ ។ ខ្ញុំគិតថារយៈពេលខ្លីបំផុតនៅក្នុងប្រទេសណាមួយគឺប្រហែល១០(ដប់)ឆ្នាំ ។ រយៈពេល ១៥ (ដប់ប្រាំ) និង២០ (ម្ភៃ) ឆ្នាំគឺសាមញ្ញ និងសេចក្តីបង្គាប់បញ្ជានៃសហាគមន៍អ៊ឺរ៉ុបថ្មីមានរយៈពេល ២៥(ម្ភៃប្រាំ)ឆ្នាំ ដើម្បីឲ្យក្លាយជាពាក្យបទដ្ឋានក្នុងបណ្តាប្រទេសនៅសហភាពអ៊ឺរ៉ុបក្នុងគ្រាដែលសេចក្តីបង្គាប់បញ្ជានោះត្រូវបានអនុវត្ត។

## សំណួរវាយតម្លៃខ្លួនឯង(SAQ)

**សំណួរវាយតម្លៃខ្លួនឯង៣(SAQ 3) ៖ តើអាយុកាលនៃកិច្ចការពារគំនូរឧស្សាហកម្មដែលផ្តល់ដោយច្បាប់នៃសហភាពអ៊ឺរ៉ុប មានរយៈពេលយូរប៉ុណ្ណា ? តើរយៈពេលអប្បបរមាយូរប៉ុណ្ណា?**

ចូរអ្នកសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ

©WIPO/OMPI

ចូរអ្នកចុចត្រង់នេះដើម្បីមើលម្លើយ

**សំណួរវាយតម្លៃខ្លួនឯង៣ ចម្លើយ ៖**

បច្ចុប្បន្ន រយៈពេលនៃកិច្ចការពារប្រែប្រួលពីរដ្ឋជាសមាជិកមួយទៅរដ្ឋជាសមាជិកមួយទៀត គ្រាដែលរដ្ឋទាំងនេះបានដំណើរការរលូនតាមច្បាប់របស់ពួកគេ ច្បាប់នេះត្រូវបានបង្កើតឡើងបាន២៥(ម្ភៃប្រាំ) ឆ្នាំមកហើយ ។

ចូរអ្នកស្តាប់ភាគនៃសម្លេងបន្ទាប់ ដើម្បីបញ្ចប់ផ្នែកគំនូរឧស្សាហកម្មដែលពន្យល់អំពីវិធីដែលប្រព័ន្ធទីក្រុងឡាអេប្រតិបត្តិការនៅក្នុងវិស័យកម្មសិទ្ធិបញ្ញា ។

**ភាគនៃសម្លេង ៨ ៖** តើរឿងបែបនេះថាជាកិច្ចការពារគំនូរឧស្សាហកម្មនៅទូទាំងពិភពលោកក្រោមកិច្ចព្រមព្រៀងទីក្រុងឡាអេ ឬ ?

ពិតជាពុំមានរឿងបែបនេះនៅទូទាំងពិភពលោកឡើយ ប៉ុន្តែការផ្តល់នូវការចុះបញ្ជីជាលក្ខណៈអន្តរជាតិពិតជាបានផ្តល់កិច្ចការពារដល់អ្នកនៅក្នុងប្រទេសមួយចំនួនមែន ។ វាដំណើរការតាមវិធីដូចគ្នាទៅនឹងប្រព័ន្ធទីក្រុងម៉ាឌ្រីដដែលអ្នកបានដាក់ពាក្យស្នើសុំចុះបញ្ជីជាលក្ខណៈអន្តរជាតិដែលត្រូវបានចុះក្នុងបញ្ជី និងត្រូវបានបោះពុម្ពដោយការិយាល័យអន្តរជាតិ និងត្រូវបានជូនដំណឹងទៅប្រទេសពាក់ព័ន្ធដែលបន្ទាប់មកមានសិទ្ធិផ្តល់ ឬបដិសេធកិច្ចការពារនោះបាន ។ តាមពិត ដំរាបណាកិច្ចព្រមព្រៀងទីក្រុងឡាអេមានការពាក់ព័ន្ធគឺ មានប្រទេសតិចតួចបំផុតដែលបានត្រួតពិនិត្យពាក្យស្នើសុំជាក់ស្តែង និងជាបន្តបន្ទាប់ទើបមានការបដិសេធតិចតួចណាស់ ។ រឿងនេះផ្ទុយទៅនឹងពាណិជ្ជសញ្ញាជាស្រុង ។

លក្ខណៈខុសគ្នាមួយទៀតរវាងកិច្ចការពារគំនូរឧស្សាហកម្ម ក្រោមកិច្ចព្រមព្រៀងទីក្រុងឡាអេ និងកិច្ចការពារម៉ាកក្រោមកិច្ចព្រមព្រៀង និងពិធីសាទីក្រុងម៉ាឌ្រីដគឺថាអ្នកមិនចាំបាច់ចាប់ផ្តើមអនុវត្តនូវកិច្ចការពារនៅក្នុងប្រទេសដើមនោះទេ ។ ដូច្នេះ ឧបមាថាអ្នកគូរគំនូរម្នាក់នៅប្រទេសបារាំងអាចធ្វើការដាក់តម្កល់ជាលក្ខណៈអន្តរជាតិបាន ហើយតាមរយៈនេះវាធានានូវកិច្ចការពារទាំងនៅប្រទេសបារាំងទាំងនៅប្រទេសស្វ៊ីស ប្រទេសអ៊ីតាលី ប្រទេសបេណឺលុច និងប្រទេសអេស្ប៉ាញផងដែរ ។

## សំណួរវាយតម្លៃខ្លួនឯង(SAQ)

ដូច្នេះ ជួនកាលកិច្ចព្រមព្រៀងទីក្រុងឡាអេអាចជួយឲ្យទទួលបាននូវកិច្ចការពារគំនូរឧស្សាហកម្មនៅក្នុងប្រទេសជាច្រើន។

©WIPO/OMPI

**សំណួរវាយតម្លៃខ្លួនឯង ៤(SAQ 4) ៖ តើកិច្ចការពារអាចត្រូវបានទទួលពីបណ្តាប្រទេសនៅលើពិភពលោក តាមមធ្យោបាយនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ ដែរឬទេ ?**

ចូរអ្នកសរសេរចម្លើយរបស់អ្នក នៅត្រង់នេះ

| |
|---|
| |

ចូរអ្នកចុចត្រង់នេះដើម្បីមើលម្លើយ

**សំណួរវាយតម្លៃខ្លួនឯង ៤(SAQ 4) ចម្លើយ ៖**

ទេ មានតែនៅក្នុងប្រទេសទាំងនោះទេដែលជារដ្ឋជាសមាជិកនៃកិច្ចព្រមព្រៀង ។ សម្រាប់ពតិមានទាន់សម័យ ចូរអ្នកមើល "ប្រទេសដែលជាភាគីនៃកិច្ចព្រមព្រៀងទីក្រុងឡាអេ" នៅលើ web site: http://www.wipo.int/hague/en របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ។

## សេចក្តីសង្ខេបមានភាពលំអៀង៖
## ប្រព័ន្ធទីក្រុងម៉ាឌ្រីត និងប្រព័ន្ធទីក្រុងឡាអេស្តីពីកិច្ចការពារនិងការចុះបញ្ជី

រហូតមកដល់ម៉ូឌុលនេះអ្នកបានយល់ដឹងអំពីកិច្ចព្រមព្រៀងពីរ របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោក ចំពោះប្រព័ន្ធចុះបញ្ជីអន្តរជាតិសម្រាប់កិច្ចការពារពាណិជ្ជសញ្ញា និងគំនូរឧស្សាហកម្ម ។ តួនាទីរបស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកក្នុងដំណើរការនេះគឺ ដើម្បីបំពេញការងារជាអ្នកគ្រប់គ្រងដែលផ្តល់ប្រព័ន្ធចុះបញ្ជីជាលក្ខណៈអន្តរជាតិ អាចនិយាយបានថា តាមរយៈការសម្របសម្រួលពាក្យស្នើសុំ និងការបោះពុម្ពព្រឹត្តប័ត្រ(ទីក្រុងម៉ាឌ្រីដ) ឬព្រឹត្តប័ត្រ(ទីក្រុងឡាអេ) ស្តីពី សកម្មភាពដែលបានអនុវត្តតាមនីតិវិធីរបស់ប្រព័ន្ធនីមួយៗ ។

ប្រព័ន្ធទីក្រុងម៉ាឌ្រីដត្រូវបានបង្កើតឡើងនៅឆ្នាំ១៨៩១ និងមានគោលបំណងលើកទឹកចិត្ត និងសម្រួលដល់ការចុះបញ្ជីពាណិជ្ជសញ្ញាជាលក្ខណៈអន្តរជាតិ ។ ជាបុគ្គលម្នាក់ចង់បានកិច្ចការពារពាណិជ្ជសញ្ញារបស់ខ្លួន គាត់ត្រូវតែចុះបញ្ជីវានៅប្រទេសដើមសិន ។ ប្រសិនបើគាត់មានបំណងចង់ពន្យារកិច្ចការពារនៅប្រទេសផ្សេងៗនោះ មានវិធីតែមួយគត់ដែលត្រូវបានផ្តល់តាមរយៈរដ្ឋជាសមាជិកនៃកិច្ចព្រមព្រៀង និង/ឬ ពិធីសារទីក្រុងម៉ាឌ្រីដ ។ មានភាពឯករាជ្យសម្រាប់៥ឆ្នាំដំបូងក្នុងករណីដែល

©WIPO/OMPI

ពាណិជ្ជសញ្ញាត្រូវបានបដិសេធយោងតាមតំណែង ឬតាមបណ្តឹងជំទាស់របស់ភាគីទីបីក្នុងប្រទេសដើម ប៉ុន្តែត្រូវបានទទួលស្គាល់ពីប្រទេសផ្សេងៗដែលបានកំណត់រួច កិច្ចការពារជាលក្ខណៈអន្តរជាតិនោះនឹងត្រូវបានបដិសេធ ។ បន្ទាប់ពីរយៈពេល៥ឆ្នាំកន្លងផុត ការចុះបញ្ជីអន្តរជាតិនឹងបន្តមានសុពលភាពចំពោះការលុបម៉ាកនោះចោលក្នុងប្រទេសដើម ។ កិច្ចការពារពាណិជ្ជសញ្ញាជាលក្ខណៈអន្តរជាតិពុំបានកំណត់ពេវេលាទេ ប៉ុន្តែកិច្ចការពារនេះត្រូវតែចុះបញ្ជីសាជាថ្មីជារៀងរាល់១០ឆ្នាំម្តង ។ ពុំមានកំណត់ពេលវេលាទេចំពោះពាណិជ្ជសញ្ញាដែលត្រូវបានចុះបញ្ជីសាជាថ្មីនោះ ។



ចូរស្តាប់ភាគនៃសម្លេងបន្ថែមចំពោះការពិពណ៌នាអំពី គោលបំណងនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ។

### ភាគនៃសម្លេង ៩ ៖ តើអ្នកអាចពន្យល់ខ្ញុំបានឬទេ អំពីន័យទូទៅចំពោះគោលបំណង និង គោលដៅនៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម ?

សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មគឺជាសន្ធិសញ្ញាមួយដែលផ្តល់សម្រាប់ការដាក់ពាក្យសុំក្នុងបំណងទទួលបានកិច្ចការពារប្រកាសនីយប័ត្រតក្កកម្មនៅក្នុងប្រទេសមួយចំនួនធំ។ វាផ្តល់នូវនីតិវិធីជួយសម្រួលដល់អ្នកបង្កើត ឬអ្នកស្នើសុំដាក់ពាក្យនិងទទួលបានប្រកាសនីយប័ត្រតក្កកម្មជាយថាហេតុ ។ បំណងប្រាថ្នានៃតក្កកម្មមួយក្នុងចំណោមតក្កកម្មផ្សេងទៀត គឺជួយជម្រុញនូវការប្រែប្រួលពតិមានផ្នែកបច្ចេកទេសដែលមាននៅក្នុងឯកសារប្រកាសនីយប័ត្រតក្កកម្ម ក្នុងចំណោមបណ្តាប្រទេសពាក់ព័ន្ធដែលជាអ្នកបង្កើតនិងការធ្វើការងារឧស្សាហកម្មក្នុងវិស័យពាក់ព័ន្ធ ។ ដូច្នេះក្រៅពីការសម្រួលដល់ដំណើរការទទួលបានប្រកាសនីយប័ត្រតក្កកម្ម វាមានបំណងចង់បានសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មដើម្បីផ្សព្វផ្សាយចំណេះដឹងលើផ្នែកបច្ចេកទេសដែលមាននៅក្នុងឯកសារប្រកាសនីយប័ត្រតក្កកម្មឲ្យកាន់តែមានប្រសិទ្ធិភាព ។ យ៉ាងណាក៏ដោយ ក៏វាមានអត្ថប្រយោជន៍ដែលប្រព័ន្ធសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មមិនបានផ្តល់នូវប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោកនោះ ។ ចូរអ្នកស្តាប់រឿងនេះដែលពន្យល់អំពីចម្លើយនៅក្នុងភាគនៃសម្លេងបន្ទាប់ ។

### ភាគនៃសម្លេង ១០ ៖ តើមានន័យថាសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មពិតជាផ្តល់នូវប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោកដល់អ្នកស្នើសុំឬ?

©WIPO/OMPI

ទេ ។មានពីរចំណុចដែលត្រូវបានផលិតនៅទីនេះ ។ ជាបឋម វាមិនមែនជាសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មទេដែលផ្តល់ប្រកាសនីយប័ត្រតក្កកម្មនោះ ។ តាមការពិត ការិយាល័យថ្នាក់ជាតិនៅចុងដំណើរការម្តងៗ ការិយាល័យនីមួយៗអាចផ្តល់ប្រកាសនីយប័ត្រតក្កកម្មបានលុះត្រាណាវាមានការពាក់ព័ន្ធដោយផ្អែកលើពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មនោះ ។ និងទី២ មិនមានរឿងបែបនេះទេថាជាប្រកាសនីយប័ត្រតក្កកម្មទូទាំងពិភពលោកនោះ ។ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មមិនបានផ្តល់គ្រប់ប្រកាសនីយប័ត្រតក្កកម្មឡើយ និងលទ្ធផលស្តីពីនីតិវិធីដែលខ្ញុំបានឡើងខាងដើមគឺពិតជាប្រកាសនីយប័ត្រតក្កកម្មថ្នាក់តំបន់ និង/ឬជាតិមួយចំនួន ។ ប្រហែលជានឹងមានតែមួយប៉ុណ្ណោះ ប្រសិនបើអ្នកស្នើសុំគ្រាន់តែបញ្ចប់នីតិវិធីនៅការិយាល័យ ប៉ុន្តែអាចមាន១០ ២៥ ៥០ ឬមានច្រើនដូចអ្នកស្នើសុំដែលមានបំណងចង់បានជាយថាហេតុនោះ ។

នៅក្នុងផ្នែកបន្ទាប់ អ្នកឧទ្ទេសនាមរៀបរាប់អំពីដំណើរការដែលកើតឡើងពេលដែលអ្នកស្នើសុំបានដាក់ពាក្យសុំកិច្ចការពារតាមលំដាប់នៃប្រទេសដែលបានកំណត់រួចហើយ ។

### ភាគនៃសម្លេង ១១៖ តើអ្នកអាចផ្តល់ជាឧទាហរណ៍គំរូស្តីពីនីតិវិធីដែលអ្នកស្នើសុំត្រូវឆ្លងកាត់បទពិសោធលើការប្រើប្រាស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម ?

ជាបឋមគេត្រូវដាក់ពាក្យសុំនៅការិយាល័យទទួលទទួលពាក្យសុំ ជាទូទៅនៅប្រទេសដើម ។ បន្ទាប់មក ពាក្យសុំនោះត្រូវឆ្លងកាត់បទពិសោធដំណាក់ការជាច្រើន ។ ជាទូទៅដំណាក់ការដំបូងហៅថាដំណាក់ការអន្តរជាតិ មានបួនជំហានសំខាន់ៗ៖ ទី១គឺ**ការដាក់ពាក្យ** ទី២គឺ**ការសិក្សាស្រាវជ្រាវជាលក្ខណ:អន្តរជាតិ** បន្ទាប់មកគឺ**ការបោះពុម្ពជាលក្ខណះអន្តរជាតិ** និងបន្ទាប់មកទៀត**ការត្រួតពិនិត្យបឋមជាលក្ខណ:អន្តរជាតិ**។ ខ្ញុំត្រូវចង្អុលបង្ហាញថាជំហានចុងក្រោយគឺការត្រួតពិនិត្យ គឺគ្រាន់តែធ្វើការសិក្សាស្រាវជ្រាវប៉ុណ្ណោះប្រសិនបើអ្នកស្នើសុំសួររឿងនេះដោយជាក់លាក់ ប៉ុន្តែ តាមបទពិសោធរបស់យើងខ្ញុំ ជាង៨០ភាគរយបន្តធ្វើមកដល់ចំណុចនេះ ។ ដូច្នេះយើងខ្ញុំពិតជាអាចនិយាយបានថាជាករណីគំរូ ពាក្យស្នើសុំសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនឹងឆ្លងកាត់បទពិសោធគ្រប់៤ជំហាននៅក្នុងដំណាក់ការអន្តរជាតិ ។ បន្ទាប់មកមានដំណាក់ការថ្នាក់ជាតិ ប៉ុន្តែប្រសិនបើអ្នកស្នើសុំគ្រាន់តែមានបំណងចង់ឲ្យពាក្យស្នើសុំរបស់គាត់មានដំណើរការទៅមុខ ។ មានដំណើរការថ្នាក់ជាតិសម្រាប់រាល់ការិយាល័យនីមួយៗមុនពេលដែលអ្នកស្នើសុំនឹងត្រូវតែបញ្ចប់នីតិវិធីផ្តល់ប្រកាសនីយប័ត្រតក្កកម្ម ។ រឿងនេះអាចមានន័យថាការិយាល័យមួយក៏បាន ឬការិយាល័យពីរក៏បាន ឬការិយាល័យប្រាំក៏បាន ឬការិយាល័យដប់ក៏បានដែលរួមមានទាំងការិយាល័យថ្នាក់ជាតិ និងការិយាល័យថ្នាក់តំបន់ ដែលអ្នកស្នើសុំត្រូវមានប្រទេសដែលបានកំណត់ពិត ប៉ុន្តែសម្រាប់គោលបំណងទទួលបានប្រកាសនីយប័ត្រតក្កកម្មថ្នាក់តំបន់ ។

©WIPO/OMPI

**ប្រកាសនីយប័ត្រតក្កកម្មសហគមន៍អ៊ឺរ៉ុប**

ដូចបានលើកឡើងនៅក្នុងកិច្ចពិភាក្សានេះដំណាក់កាលធម្មតា នៃសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មទី២គឺដំណាក់កាលថ្នាក់ជាតិ ។ នៅដំណាក់កាលថ្នាក់ជាតិ អ្នកស្នើសុំពិតជាអាចដំណើរការពាក្យស្នើសុំអន្តរជាតិរបស់គាត់ ឬរបស់នាងបានមុនការិយាល័យប្រកាសនីយប័ត្រតក្កកម្មថ្នាក់ជាតិ ឬថ្នាក់តំបន់។ ប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុបគឺជាឧទាហរណ៍មួយស្ដីពីការិយាល័យថ្នាក់តំបន់បែបនេះ ។

ប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុបត្រូវបានបង្កើតឡើងពីព្រោះតែអនុសញ្ញាប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុប ។ មាត្រា២(១)នៃអនុសញ្ញាប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុបនេះបានចែងថាប្រកាសនីយបត្រតក្កកម្មបានផ្ដល់ឲ្យពីព្រោះអនុសញ្ញា"ត្រូវបានគេហៅថាប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុប" ។មាត្រា២(២)ថែមទៀតបានចែងថា "ប្រកាសនីយបត្រតក្កកម្មសហគមន៍អ៊ឺរ៉ុបត្រូវចូលជាធរមាន និងអនុលោមតាមល័ក្ខខ័ណ្ឌតែមួយដូចប្រកាសនីយបត្រតក្កកម្មថ្នាក់ជាតិដែលផ្ដល់ដោយរដ្ឋនោះដែរ ម្យ៉ាងទៀតដរាបណាមានចែងនៅក្នុងអនុសញ្ញានេះ នៅក្នុងរដ្ឋហត្ថលេខីដែលរដ្ឋនោះផ្ដល់ឲ្យ។"

<u>សូមចុចត្រង់នេះដើម្បីមើលបញ្ជីឈ្មោះរដ្ឋហត្ថលេខីEPC</u>។

**សំណួរវាយតម្លៃខ្លួនឯង១ (SAQ 1)**

**សំណួរវាយតម្លៃខ្លួនឯង៥(SAQ5)៖គូរឌីយ៉ាក្រាមដែលបង្ហាញអំពី ដំណើរការពាក់ព័ន្ធនៅពេលដែលអ្នកស្នើសុំប្រើប្រាស់សន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្ម(PCT)។**

ចូរអ្នកសរសេរចម្លើយរបស់អ្នកនៅត្រង់នេះ

| |
|---|
| |

ចូរអ្នកចុចត្រង់នេះដើម្បីមើលចម្លើយ

©WIPO/OMPI


អ្នកស្នើសុំដាក់ពាក្យស្នើសុំ ដែល
កំណត់អំពីប្រទេសទទួលផលកម្រៃ
ការស្រាវជ្រាវ
ជាលក្ខណៈអន្តរជាតិ
ការបោះពុម្ព
ជាលក្ខណៈអន្តរជាតិ
ដំណាក់ការអន្តរជាតិ
ការត្រួតពិនិត្យបឋម
ជាលក្ខណៈអន្តរជាតិ
អ្នកស្នើសុំជ្រើសរើស
ប្រទេសដែលបានកំ
ណត់ដែលប្រទេស
ទាំងនោះនៅតែ
ទទួលផលកម្រៃ
ដំណាក់ការជាតិ
ប្រទេស ក
ប្រទេស ខ
ប្រទេស គ
ប្រទេស ឃ
ប្រទេស ង

©WIPO/OMPI

ដូច្នេះ ប្រតិបត្តិការសន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្មតម្រូវឲ្យមានដំណើរការនៃប្រតិបត្តិការបន្តគ្នា និងភាគនៃសម្លេងបន្ទាប់ដែលពន្យល់អំពីបញ្ហាទាំងនេះកើតមានឡើង ។

**ភាគនៃសម្លេង ១២ ៖ អ្នកបានលើកឡើងថាមានបី ឬបួនជំហាននៅក្នុងដំណាក់ការអន្តរជាតិ ដែលពាក់ព័ន្ធនឹងបញ្ហាស្រាវជ្រាវ និងបញ្ហាផ្សេងៗទៀត ។ តាមពិត តើបញ្ហានេះកើតមាននៅទីណា ? តើវាត្រូវធ្វើនៅទីក្រុងហ្សឺណែវ ឬ ?**

ទេ ។ អ្វីដែលកើតឡើងភាគច្រើននៅក្នុងដំណើរការសន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្មចាប់ផ្តើមនៅទីកន្លែងខ្លះទៀត និងបន្តម្តងទៀតនៅទីកន្លែងខ្លះទៀតនោះ ។ ជាបឋម អ្នកស្នើសុំនឹងដាក់ពាក្យស្នើសុំនៅការិយាល័យមួយដែលមានឈ្មោះថាការិយាល័យទទួលពាក្យ ។ តាមពិត ជាទូទៅគឺជាការិយាល័យនៅប្រទេសដើមរបស់អ្នកស្នើសុំ ។ ប៉ុន្តែវាអាចជាការិយាល័យថ្នាក់ជាតិ ឬការិយាល័យថ្នាក់តំបន់មួយទៀត និងវាអាចជាការិយាល័យអន្តរជាតិនៅទីក្រុងហ្សឺណែវផងដែរ ។ ដូច្នេះវាអាចកើតឡើងបានដែលការិយាល័យអន្តរជាតិមានការពាក់ព័ន្ធទៅនឹងរាល់ដំណាក់ការដំបូង ប៉ុន្តែវាមិនមែនសាមញ្ញណាស់នោះទេ ។

ចំណែកជំហានទី២គឺជាជំហានស្រាវជ្រាវអន្តរជាតិ បច្ចុប្បន្នមានត្រឹម១១ការិយាល័យ ជាពិសេសតែងតាំងដោយមហាសន្និបាត នៃសន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្ម ដែលមានសិទ្ធិអនុវត្តការស្រាវជ្រាវអន្តរជាតិ ។ ការិយាល័យទាំងនេះហៅថាអាជ្ញាធរស្រាវជ្រាវអន្តរជាតិដែលត្រូវបានជ្រើសរើសអនុលោមតាមលក្ខណៈវិនិច្ឆ័យពិតប្រាកដ ហើយពួកគេផ្តល់សេវាកម្មដល់អ្នកស្នើសុំក្រោមប្រព័ន្ធសន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្ម ក្នុងករណីសេវាកម្មខ្លះផ្អែកលើភាសាដែលពួកគេធ្វើការងារ ។ ដូច្នេះពួកគេពុំមានពេលវេលាគ្រប់គ្រាន់សម្រាប់អ្នកស្នើសុំទាំងអស់ដែលបានដាក់ពាក្យស្នើសុំនោះ ។ ឧទាហរណ៍ដូចជាការិយាល័យប្រកាសនីយប័ត្រតក្កកម្មជប៉ុនធ្វើការងារជាប្រជាជនជប៉ុនប៉ុណ្ណោះ ដូច្នេះពុំមានពេលវេលាសម្រាប់អ្នកស្នើសុំដែលដាក់ពាក្យស្នើសុំរបស់ខ្លួនជាភាសាអង់គ្លេស ភាសាបារាំង ឬភាសាអាល្លឺម៉ង់នោះឡើយ។ ដូចគ្នានេះដែរគឺជារឿងពិតចំពោះការិយាល័យប្រកាសនីយប័ត្រតក្កកម្ម និងពាណិជ្ជសញ្ញាអេស្បាញដែលធ្វើការងារសម្រាប់តែប្រជាជនអេស្បាញប៉ុណ្ណោះ ។ ម្យ៉ាងទៀត ការិយាល័យដទៃខ្លះទៀតធ្វើការងារបួន ប្រាំ ឬប្រាំមួយភាសាខុសៗគ្នា ។

ដូច្នេះ ប្រតិបត្តិការសន្ធិសញ្ញាសហប្រត្តិការប្រកាសនីយប័ត្រតក្កកម្មតម្រូវឲ្យមានដំណើរការនៃប្រតិបត្តិការបន្តគ្នា និងភាគនៃសម្លេងបន្ទាប់ដែលពន្យល់អំពីបញ្ហាទាំងនេះកើតមានឡើង ។

ជំហានទី៤គឺការត្រួតពិនិត្យបឋមជាលក្ខណៈអន្តរជាតិ ហើយសម្រាប់អង្គការ កម្មសិទ្ធិបញ្ញាពិភពលោក(WIPO)នោះ ជាទូទៅនឹងវិលទៅរកការិយាល័យដែលអនុវត្តការស្រាវជ្រាវជាលក្ខណៈ អន្តរជាតិ ។ តាមធម្មតាខ្ញុំលើកឡើងនេះពីព្រោះអ្នកស្នើសុំអាច និងក្នុងករណីខ្លះធ្វើ

©WIPO/OMPI

ការផ្លាស់ប្តូរទៅការិយាល័យមួយទៀតខណៈដែលពួកគេត្រូវបានផ្តល់នូវលទ្ធភាពដែលអាចបត់បែនបាន ។ ហើយនៅចុងបញ្ចប់ដំណាក់ការអន្តរជាតិ ឬពេលដែលចូលទៅក្នុងដំណាក់ការថ្នាក់ជាតិដែរ ហើយដែលបញ្ហានេះជាបញ្ហាអ្វីមួយទៀតដែលការិយាល័យអន្តរជាតិពុំមានការពាក់ព័ន្ធនោះ ដែលអ្នកស្នើសុំត្រូវតែរកវិធីដោះស្រាយដោយផ្ទាល់ក្នុងចំណោមការិយាល័យនីមួយៗ និងផ្តល់ឯកសារចាំបាច់ ។ គេអាចនិយាយបានថា ទោះយ៉ាងដូច្នេះក្តីក៏ការិយាល័យអន្តរជាតិមានការពាក់ព័ន្ធជាអាចិកំបាំងខ្លះទៅនឹងនីតិវិធីទាំងស្រុង ពីព្រោះការិយាល័យនេះទទួលបន្ទុកធ្វើឯកសារពិតសម្រាប់ការិយាល័យ ឬអ្នកស្នើសុំ។ល។ ប្រើប្រាស់និងជូនកាលសម្រាប់ធ្វើការទំនាក់ទំនងឯកសារពិតក្រោមបទប្បញ្ញតិនៃសន្ធិសញ្ញានេះ ។ ដូច្នេះ ទោះជាការិយាល័យអន្តរជាតិមិនបានដាក់ទំងន់ទៅលើការងារដ៏មានសារៈសំខាន់នោះក៏ដោយ ក៏ការិយាល័យនេះមានការពាក់ព័ន្ធនៅក្នុងដំណាក់ការនេះដែរនូវអ្វីដែលកើតឡើងចំពោះអ្នកស្នើសុំនោះ។ ការិយាល័យនេះពឹងលើការិយាល័យពាក់ព័ន្ធដើម្បីផ្តល់ឯកសារមកឲ្យការិយាល័យនេះវិញ រួចហើយអនុវត្តតាមឯកសារទាំងនោះខណៈដែលឯកសារទាំងនោះត្រូវបានទទួល ។

### សំណួរវាយតម្លៃខ្លួនឯង(SAQ)

**សំណួរវាយតម្លៃខ្លួនឯង៦ ៖** សកម្មភាពដូចតទៅនេះ តើសកម្មភាពមួយណាដែលតែងតែត្រូវបានអនុវត្តដោយការិយាល័យអន្តរជាតិនៅទីក្រុងហ្សឺណែវ ដែលមើលទៅអនុវត្តដោយការិយាល័យអន្តរជាតិនោះ និងសកម្មភាពមួយណាដែលមិនដែលអនុវត្តទាល់តែសោះដោយការិយាល័យអន្តរជាតិនោះ ?

ក) ការទទួលពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្ម

ខ) ការទទួលពាក្យស្នើសុំសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម

គ) ការស្រាវជ្រាវជាលក្ខណៈអន្តរជាតិ

ឃ) ការបោះពុម្ពជាលក្ខណៈអន្តរជាតិ

ច) ការត្រួតពិនិត្យបឋមជាលក្ខណៈអន្តរជាតិ

ឆ) ការផ្តល់ប្រកាសនីយប័ត្រតក្កកម្មថ្នាក់ជាតិ ឬថ្នាក់តំបន់

ចូរអ្នកសេសេរម្លើរបស់អ្នកនៅត្រង់នេះ ៖

©WIPO/OMPI

ចុចត្រង់នេះដើម្បីមើលចម្លើយ ៖

**សំនួរវាយតម្លៃខ្លួនឯង ៦ ចម្លើយ ៖**

ក) មិនដែល

ខ) ប្រហែលជា

គ) មិនដែល

ក) ជានិច្ច / ជាដរាប

ខ) មិនដែល

គ) មិនដែល

ដូចបានកំណត់នៅក្នុងសេចក្តីផ្តើម គោលដៅបឋមរបស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មគឺ ជួយសម្រួលនីតិវិធីពាក់ព័ន្ធក្នុងការទទួលបានប្រកាសនីយប័ត្រតក្កកម្មក្នុងបណ្តាប្រទេសផ្សេងៗមួយចំនួន ។ រីឯផលប្រយោជន៍បន្ថែមចំពោះអ្នកស្នើសុំគឺការសម្រេចថាតើអាចដំណើរការបាន ឬត្រូវពន្យារពេលនៅក្នុងប្រទេសពិសេសណាមួយចំពោះនីតិវិធីនោះ បើប្រៀបធៀបទៅនឹងប្រព័ន្ធប្រកាសនីយប័ត្រតក្កកម្មប្រពៃណី ។

**ភាគនៃសម្លេង ១៣ ៖** យល់ព្រម ដូច្នេះតើមានអត្ថប្រយោជន៍អ្វីខ្លះចំពោះបុគ្គល ឬក្រុមហ៊ុនដែលដាក់ពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្ម ក្រោមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មនោះ?

ខ្ញុំសូមនិយាយអំពីអត្ថប្រយោជន៍សំខាន់សម្រាប់អ្នកស្នើសុំគឺថាគាត់នឹងទទួលបានកាលបរិច្ឆេទដាក់ពាក្យអន្តរជាតិសម្រាប់ពាក្យស្នើសុំរបស់គាត់តាមរយៈការដាក់ពាក្យស្នើសុំនៅការិយាល័យប្រកាសនីយប័ត្រតក្កកម្មមួយ ដែលក្នុងករណីភាគច្រើននៅការិយាល័យប្រកាសនីយបត្រតក្កកម្មក្នុងស្រុករបស់គាត់ហើយកាលបរិច្ឆេទការដាក់ពាក្យនោះនឹងចូលជាធរមានស្តីពីការដាក់ពាក្យស្នើសុំថ្នាក់ជាតិបានត្រឹមត្រូវនៅរាល់ប្រទេសដែលបានកំណត់រួចហើយ ។ ដូច្នេះលក្ខណៈចាំបាច់ដែលអ្នកស្នើសុំត្រូវតែអនុលោមតាមនោះគឺ មានតិចតួចបំផុតដូចជាការធ្វើសំណូមពរជាក់លាក់ចំពោះការដាក់ពាក្យស្នើសុំសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មដែលកំណត់អំពីសញ្ជាតិ ឫទីលំនៅរបស់គាត់ដើម្បីបញ្ជាក់ថាគាត់មានសិទ្ធិដាក់ស្នើសុំបែបនេះ និងការដាក់ពាក្យស្នើសុំស្តីអំពីការពិពណ៌នា និងការទាមទារ ។ តាមរយៈការដាក់ពាក្យស្នើសុំរបស់គាត់ អត្ថប្រយោជន៍ដ៏មានតម្លៃមួយទៀតគឺអ្នកស្នើសុំចំណេញពេលវេលា និងមានពេលវេលាច្រើន មុនពេលដែលគាត់ត្រូវសម្រេចចិត្តថាត់ត្រូវដំណើរការពាក្យស្នើសុំរបស់គាត់បន្តទៀត ។ ពេលវេលាដែលគាត់ទទួលបានតាមរយៈដំណើរការនេះគឺប្រហែលមួយឆ្នាំកន្លះ ចំពោះកិច្ច

©WIPO/OMPI

ដំណើរការ នៃការប្រើប្រាស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មទាំងស្រុងនូវវិសាលភាពពេញលេញបំផុតដែលអាចត្រូវបានអនុញ្ញាត ។

[**កំណត់សំគាល់ ៖** កំណត់ហេតុស្តីពីភាគនៃសម្លេងដែលត្រូវបានធ្វើឲ្យទំនើបចំពោះពត៌មានបច្ចុប្បន្ន]

បន្ថែមពីលើនេះ មានអត្ថប្រយោជន៍ផងដែរសម្រាប់ការិយាល័យប្រកាសនីយប័ត្រតក្កកម្មថ្នាក់ជាតិ ។ គឺ ៖

ការិយាល័យប្រកាសនីយប័ត្រតក្កកម្មទាំងឡាយអាចរកវិធីដោះចំពោះពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មអោយបានកាន់តែច្រើនចាប់តាំងពីពេលដែលពាក្យស្នើសុំប្រកាសនីយប័ត្រតក្កកម្មទាំងនោះត្រូវបានឆ្លងតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មដែលមានលក្ខណៈងាយស្រួលដំណើរការតាមពេលវេលាកំណត់ ជាពិសេសចំពោះហេតុការណ៍នៃការផ្ទៀងផ្ទាត់អំពីអនុលោមភាពទៅនឹងលក្ខខណ្ឌផ្លូវការដែលជាទូទៅត្រូវបានត្រួតពិនិត្យរួចហើយនៅក្នុងដំណាក់ការអន្តរជាតិ។

ការិយាល័យប្រកាសនីយប័ត្រតក្កកម្មទាំងឡាយអាចសន្សំប្រាក់ថ្លៃបោះពុម្ពជាក់ស្តែងបាន ។ ក្នុងករណីដែលការិយាល័យអន្តរជាតិត្រូវបានបោះពុម្ពជាភាសាផ្លូវការនេះប្រទេសមួយប្រទេសនោះអាចដំណើរការទាំងស្រុងបាន ។ ប្រទេសទាំងឡាយមានភាសាខុសៗគ្នា និងអាចកំណត់ដោយខ្លួនឯងចំពោះការបោះពុម្ព មានតែការបកប្រែសង្ខេបប៉ុណ្ណោះដែលត្រូវភ្ជាប់មកជាមួយនឹងពាក្យស្នើសុំជាលក្ខណៈអន្តរជាតិនោះ ។ ច្បាប់ចម្លងអត្ថបទពាក្យស្នើសុំជាលក្ខណៈអន្តរជាតិពេញលេញអាចត្រូវបានផ្តល់តាមសំណូមពររបស់ភាគីទីបី។

សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្ម មិនប៉ះពាល់ដល់ប្រាក់ចំណូលរបស់ការិយាល័យដែលបានកំណត់រួចនោះឡើយ ដ៏រាបណាការិយាល័យទាំងនោះសម្រេចដោយស្ម័គ្រចិត្តក្នុងការផ្តល់កម្រៃថ្នាក់ជាតិ ពីព្រោះប្រាក់សន្សំអនុវត្តតាមសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មនិង ដើម្បីធ្វើការប្រើប្រាស់ពាក្យស្នើសុំជាលក្ខណៈអន្តរជាតិនោះមានភាពទាក់ទាញច្រើនដល់អ្នកស្នើសុំ ។ កម្រៃប្រចាំឆ្នាំនិងកម្រៃចុះបញ្ជីសាជាថ្មីមិនធ្វើឲ្យប៉ះពាល់ដល់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មឡើយ។

ការត្រួតពិនិត្យរបស់ការិយាល័យប្រកាសនីយប័ត្រតក្កកម្ម ទទួលបានផលប្រយោជន៍ពីរបាយការណ៍អន្តរជាតិនិងរបាយការណ៍ត្រួតពិនិត្យបឋមចំពោះពាក្យស្នើសុំភាគច្រើនដែលមានប្រភព

©WIPO/OMPI

ពីបរទេស ។

ការិយាល័យដែលមិនបានធ្វើការត្រួតពិនិត្យ ទទួលពាក្យស្នើសុំដែលបានពិនិត្យរួចស្តីពីទម្រង់បែបបទដែលភ្ជាប់មកជាមួយនឹងរបាយការណ៍ស្រាវជ្រាវជាលក្ខណៈអន្តរជាតិ និងជាទូទៅតាមរយៈរបាយការណ៍ត្រួតពិនិត្យបឋមជាលក្ខណៈអន្តរជាតិ ។ រឿងនេះនឹងទុកឲ្យការិយាល័យមួយធ្វើការដោះស្រាយ និងឧស្សាហកម្មថ្នាក់ជាតិដែលធ្វើឲ្យប៉ះពាល់ដល់ប្រកាសនីយបត្រតក្កកម្ម និងឬនាំដល់ការចេញវិញ្ញាបនបត្រក្នុងស្ថានការណ៍មួយដ៏ល្អប្រសើរបើប្រធៀបទៅនឹងប្រព័ន្ធដែលមានលក្ខណៈប្រពៃណីនៃការដាក់ពាក្យស្នើសុំថ្នាក់ជាតិ ឬថ្នាក់តំបន់ ។

## សេចក្តីសង្ខេប

កិច្ចសហប្រតិបត្តិការប្រកាសនីយបត្រតក្កកម្មផ្តល់នីតិវិធីងាយៗដល់អ្នកបង្កើតឬអ្នកស្នើសុំដាក់ពាក្យ និងទទួលបានប្រកាសនីយប័ត្រតក្កកម្មជាយថាហេតុនៅក្នុងប្រទេសមួយចំនួនធំ ។ លើសពីនេះ វាជួយជម្រុញនិងជួយសម្រួលដល់ការផ្លាស់ប្តូរពត៌មានខាងផ្នែកបច្ចេកទេស ដែលមាននៅក្នុងឯកសារប្រកាសនីយប័ត្រតក្កកម្មស្តីពីឧស្សាហកម្ម និងកម្មករក្នុងវិស័យដែលពាក់ព័ន្ធ ។

អត្ថប្រយោជន៍ចំពោះអ្នកស្នើសុំ ក្នុងការប្រើប្រាស់សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មគឺគេនឹងទទួលបានកាលបរិច្ឆេទ នៃការដាក់ពាក្យស្នើសុំអន្តរជាតិតាមរយៈការដាក់ពាក្យស្នើសុំនៅការិយាល័យប្រកាសនីយប័ត្រតក្កកម្មមួយ ហើយកាលបរិច្ឆេទនៃការដាក់ពាក្យស្នើសុំនោះនឹងចូលជាធរមានសម្រាប់ប្រទេសដែលបានកំណត់រួចហើយ ។ លើសពីនេះ សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មបានកំណត់អំពីរយៈពេលក្នុងនោះអ្នកស្នើសុំអាចធ្វើការសម្រេចចិត្ត ថាតើត្រូវដំណើរការក្នុងប្រទេសនីមួយៗដែលបានកំណត់រួចហើយដោយរបៀបណា ។

តួនាទីសំខាន់របស់អង្គការកម្មសិទ្ធិបញ្ញាពិភពលោកក្នុងដំណើរការសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មគឺ ដើម្បីជួយសម្រួលដល់សន្ធិសញ្ញាតាមរយៈការទំនាក់ទំនងសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មស្នើទៅប្រទេសដែលបានកំណត់រួចហើយនោះ និងតាមរយៈការបោះពុម្ពពាក្យស្នើសុំសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មទាំងអស់ ។

វិធីដែលពាក្យស្នើសុំសន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្មត្រូវបានដំណើរការ និងត្រូវបានបង្ហាញនៅក្នុងរូប ដូចតទៅនេះ ៖

©WIPO/OMPI




**អត្ថបទនៃនីតិបញ្ញត្តិ ៖**

. កិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ ស្តីពី ការចុះបញ្ជីម៉ាកអន្តរជាតិ

©WIPO/OMPI

. ពិធីសារដែលពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងទីក្រុងម៉ាឌ្រីដ ស្តីពី ការចុះបញ្ជីម៉ាកអន្តរជាតិ

. កិច្ចព្រមព្រៀងទីក្រុងឡាអេ ស្តីពី ការដាក់តម្កល់គំនូរឧស្សាហកម្មអន្តរជាតិ

. កិច្ចព្រមព្រៀងទីក្រុងនីស ស្តីពី ចំណាត់ថ្នាក់ទំនិញ និងសេវាអន្តរជាតិសម្រាប់គោលបំណងចុះបញ្ជីម៉ាក

. សន្ធិសញ្ញាសហប្រតិបត្តិការប្រកាសនីយប័ត្រតក្កកម្ម(PCT) ។

©WIPO/OMPI